**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

3

# កិច្ចព្រមព្រៀង

**រវាង**

**រោងចក្រ សាន់រ៉ាន់ (ខេមបូឌា) ហ្គាម៉ិន**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពប្រជាធិបតេយ្យឯករាជ្យកម្មករខ្មែរប្រចាំ**

**រោងចក្រ សាន់រ៉ាន់ (ខេមបូឌា) ហ្គាម៉ិន**

## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០២០ វេលាម៉ោង ១០៖០០នាទី នៅក្នុងរោងចក្រ **សាន់រ៉ាន់ (ខេមបូឌា) ហ្គាម៉ិន** មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះការបញ្ជារទិញ ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន ហេតុដូចនេះក្រុមហ៊ុន សម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន **១៧៦នាក់** រយៈពេលចំនួន **២ខែ** គឺចាប់ពី**ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០** រហូតដល់**ថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០២០** នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឧបត្ថម្ភចំនួន ៣០(សាមសិប) ដុល្លាអាមេរិកក្នុងមួយខែសម្រាប់កម្មករនិយោជិតម្នាក់ៗ។

អង្គប្រជុំបានចប់វេលាម៉ោង១១ និង ០០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ភ្នំពេញ.ថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ ២០២០

**តំណាងកម្មករ និង តំណាងសហជីព**

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
សាន់រ៉ាន់ (ខេមបូឌា) ហ្គាម៉ិន
SUNRUN (CAMBODIA) GARMENTS
KINGDOM OF CAMBODIA

杨文杰

YANG WENJIE

ឈ្មោះ ម៉េង ទី

ឈ្មោះ វ៉ា សុមៀន

ឈ្មោះ ចេក ទីណា

ឈ្មោះ តី រដ្ឋា

ឈ្មោះ ស៊ូ សារ៉ាក់

ឈ្មោះ គឹម ស្រីតូច